00743668

E125

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 09 / 2011
ម៉ោង (Time/Heure): 13:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង សាធារណៈ / Public

ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១

**ជូនចំពោះ:** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង, ភាគីទាំងអស់នៃសំណុំរឿងលេខ ០០២ និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារ ដោយអនុលោមតាមវិធាន២៣ *ស្ទួនបួន*(៣)នៃវិធានផ្ទៃក្នុង

យោងដីការបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានចេញមុនពេលសវនាការបឋម (ឯកសារ E86 និង ឯកសារ E86/1) ដែលដីកាទាំងនោះបានស្នើសុំឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបញ្ជាក់បឋមអំពីខ្លឹមសារជាក់លាក់នៃសំណង ដែលខ្លួនមានបំណងស្នើសុំនៅក្នុងបណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្ត និងសមូហភាព អនុលោមតាមវិធាន៨០ ស្ទួន (៤) និង វិធាន២៣ ស្ទួនបួន (៣) (ខ) នៃវិធានផ្ទៃក្នុង។

ដើម្បីឱ្យមានភាពងាយស្រួល អង្គជំនុំជម្រះសាលាដំបូងសូមរំឭកអំពីចំណុចជាសារវ័ន្តមួយចំនួនស្តីពីគម្រោងនៃសំណងដែលត្រូវបានដាក់បញ្ចូលទៅក្នុងវិធានផ្ទៃក្នុង ដោយកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក កាលពីខែ កញ្ញា ឆ្នាំ ២០១០ កន្លងមក៖

### ក) *សោហ៊ុយនៃសំណងត្រូវតែជាបន្ទុករបស់ពិរុទ្ធជន (វិធាន ២៣ ស្ទួនបួន (៣)(ក) នៃវិធានផ្ទៃក្នុង)*

សំណងរដ្ឋប្បវេណី "ដែលធ្លាប់អនុវត្ត" ធ្វើឡើងប្រឆាំងនឹងជនជាប់ចោទនោះ គឺត្រូវបានរក្សាទុកនៅក្នុងវិធានផ្ទៃក្នុងដដែល (វិធាន ២៣*ស្ទួនបួន*(៣)(ក))។ សំណងនេះត្រូវអនុវត្តដោយតុលាការជាតិ ប្រសិនបើពិរុទ្ធជនមិនព្រមអនុវត្តសំណងនោះដោយស្ម័គ្រចិត្ត។ តាមច្បាប់កម្ពុជា សំណងរដ្ឋប្បវេណីដែលត្រូវអនុវត្តដោយតុលាការគឺត្រូវតែបំពេញទៅតាមលក្ខខណ្ឌគតិយុត្តិដែលបានតម្រូវ (រួមទាំងការបង្ហាញពីភាពជាក់លាក់នៃសំណង)។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបង្ហាញនូវទស្សនៈរបស់ខ្លួនម្តងរួចហើយលើបញ្ហានេះនៅក្នុងសាលក្រមនៃសំណុំរឿងលេខ ០០១ (សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ករណី *ឌុច* កថាខណ្ឌ ៦៦១)។ រាល់ការទាមទារសំណងដែលធ្វើឡើងតាមបញ្ញត្តិនេះ គឺត្រូវធ្វើយ៉ាងយូរបំផុតក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល។ អនុស្សរណៈនេះពុំពាក់ព័ន្ធនឹងការទាមទារសំណងតាមវិធាន២៣*ស្ទួនបួន*(៣)(ក) នោះទេ។

### ខ) *ការបង្កើតគម្រោងសំណងដោយមានកិច្ចសហការជាមួយអង្គភាពគាំពារជនរងគ្រោះ និងការខបត្ថម្ភគាំទ្រជាថវិកាពីប្រភពខាងក្រៅ (វិធាន២៣ស្ទួនបួន(៣)(ខ))*

ដោយសារភាពមិនច្បាស់លាស់នៃការទទួលបានសំណងរដ្ឋប្បវេណីតាមរយៈវិធីសាស្ត្រ "ដែលធ្លាប់អនុវត្ត" នោះ ទើបមធ្យោបាយថ្មីមួយដែលមានលក្ខណៈឯករាជ្យត្រូវបានបង្កើតឡើង (វិធាន ២៣*ស្ទួនបួន*(៣)(ខ)នៃវិធានផ្ទៃក្នុង)។ គម្រោងសំណងទាំងនេះមិនអាចបង្កើតបានជាការទាមទារសំណងដែលអាចអនុវត្តបាន ប្រឆាំងនឹងជនជាប់ចោទបានទេ។

គោលគំនិតខាងលើត្រូវបានបង្កើតឡើងដើម្បីធានាថា សំណងជាក់ស្តែងដែលផ្តល់ដោយប្រភពខាងក្រៅ ដែលបានទទួលស្គាល់ព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានអនុវត្តដោយឆាប់រហ័សក្រោយពេលសាលក្រមចូលជាស្ថាពរ។ ចំណុចនេះតម្រូវឱ្យមានការរៀបចំសំណង (ជាលក្ខណៈបច្ចេកទេសតាមរយៈការគ្រប់គ្រងគម្រោង) ក្នុងពេលដំណាលគ្នាទៅនឹងដំណើរការសវនាការ។ ដោយហេតុថាអង្គភាពគាំពារជនរងគ្រោះបាននឹងកំពុងធ្វើការលើកិច្ចការមួយចំនួន ដែលជាវិធានការក្រៅតុលាការ ទើបការប្រគល់ការងារបង្កើតគម្រោងពាក់ព័ន្ធនឹងវិធាន ២៣*ស្ទួនបួន*(៣)(ខ) ទៅឱ្យអង្គភាពនេះគឺជាជម្រើសមួយជាក់ស្តែង។ អង្គភាពគាំពារជនរងគ្រោះបានតែងតាំងមន្ត្រីគ្រប់គ្រងគម្រោងម្នាក់ ដើម្បីធ្វើការអភិវឌ្ឍទម្រង់នៃសំណងទាំងអស់នេះ។ មន្ត្រីគ្រប់គ្រងគម្រោងនេះត្រូវរៀបចំនូវទម្រង់នៃសំណងដែលបានចង្អុលបង្ហាញដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវធានាលើបញ្ហាថវិកា និងការត្រៀមខ្លួនរួចជាស្រេចក្នុងការអនុវត្តនូវសំណងនេះនៅពេលសាលក្រមចូលជាស្ថាពរ។ ដើម្បីធានាថាបណ្តឹងទាមទារសំណងទាំងអស់នេះ

មានលក្ខណៈប្រាកដប្រជាតាមបច្ចេកទេស មានតួលេខច្បាស់លាស់ និងមានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់អនុវត្ត គប្បីត្រូវមានកិច្ចសហការស្អិតរមួតរវាងមន្ត្រីគ្រប់គ្រងគម្រោងកម្មវិធីសំណង និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចាប់តាំងពីដំណាក់កាលដំបូង។ សូមបញ្ជាក់ថា អង្គជំនុំជម្រះពុំមានចេតនាចង់ឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកទទួលបន្ទុកលើកិច្ចការបង្កើតគម្រោងសំណង ឬការស្វែងរកថវិកានោះឡើយ។

ដើម្បីជៀសវាងនូវការបង្កើតគម្រោងដែលត្រូវចំណាយថវិកាច្រើន ចំណាយពេលវេលាច្រើន ឬការបង្ហាញមានភាពមិនច្បាស់លាស់ ហើយដែលអាចត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន២៣*ក្វាទ្រូប*(៣)(ខ) នោះ ទើបការតម្រូវឱ្យមានការបញ្ជាក់ជាមុនអំពីខ្លឹមសារជាក់លាក់ស្តីពីសំណងនៅដំណាក់កាលដំបូងត្រូវបានបង្កើតឡើង (វិធាន ៨០*ស្ទួន*(៤))។ ប្រការនេះអាចអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូង លើកឡើងនូវកង្វល់នានានៅដំណាក់កាលដំបូង នៅពេលដែលការផ្លាស់ប្តូរគម្រោងសំណងនេះនៅអាចធ្វើបាន។ អង្គជំនុំជម្រះយល់ថា ការបញ្ជាក់ជាមុននេះគឺជាផ្នែកមួយដ៏សំខាន់ ដើម្បីធានាថាវិធានការមួយចំនួនដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿងលេខ ០០២ គឺស្ថិតនៅក្នុងវិសាលភាពនៃវិធានផ្ទៃក្នុង ហើយអាចនាំមកនូវលទ្ធផលជាផ្លែផ្កាសម្រាប់ជនរងគ្រោះ និងដើម្បីធានាថាអង្គភាពគាំពារជនរងគ្រោះ និងម្ចាស់ជំនួយខាងក្រៅពិតជាបានប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព។ គោលបំណងផ្សេងទៀតនៃការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងនេះគឺដើម្បីទុកឱកាសឱ្យអង្គជំនុំជម្រះពិនិត្យមើល ថាតើសំណងដែលបានស្នើសុំនោះស្របជាមួយក្របខណ្ឌតុលាការរបស់ អ.វ.ត.ក ដែរឬទេ និងដើម្បីឱ្យអង្គជំនុំជម្រះមានលទ្ធភាពផ្តល់ការណែនាំចាប់តាំងពីដំណាក់កាលដំបូង ក្នុងករណីចាំបាច់។

វិធាន ៨០*ស្ទួន*(៥) នៃវិធានផ្ទៃក្នុងបញ្ជាក់ថា ប្រសិនបើការដាក់បណ្តឹងទាមទារចុងក្រោយសម្រាប់សំណងផ្លូវចិត្ត និងសមូហភាព អាចមានភាពខុសគ្នាពីការទាមទារលើកដំបូង តាមភាពចាំបាច់ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីខ្លឹមសារនៃការទាមទារ និងរបៀបនៃការអនុវត្តសំណងនីមួយៗ។ ដោយសារតែការយល់មិនច្បាស់អំពីទស្សនាទាននេះ ទើបនៅក្នុងពេលសវនាការបឋម សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់ទៅនឹងសំណើរបស់អង្គជំនុំជម្រះ ដែលបានស្នើសុំឱ្យសហមេធាវីនាំមុខធ្វើការបញ្ជាក់លម្អិតអំពីខ្លឹមសារនៃសំណង និងរបៀបនៃការអនុវត្តសំណងនោះ (ប្រតិចារឹក, ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១១, ទំព័រ ១០០,១១០ (អត្ថបទជាភាសាអង់គ្លេស))។

អង្គជំនុំជម្រះសូមបញ្ជាក់ថាគោលបំណងនៃការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងនេះ គឺដើម្បីជំរុញឱ្យមានភាពច្បាស់លាស់គ្រប់គ្រាន់ និងការរៀបចំផែនការជាមុន ធ្វើយ៉ាងណាដើម្បីធានាថាដើមបណ្តឹង

រដ្ឋប្បវេណីទទួលបានសំណងប្រកបដោយអត្ថន័យនៅក្នុងក្របខណ្ឌអាណត្តិរបស់ អ.វ.ត.ក។ ដូច្នេះ ការបញ្ជាក់ជូនអង្គជំនុំជម្រះអំពីខ្លឹមសារនៃសំណងឲ្យបានច្បាស់លាស់ តាមដែលអាចធ្វើទៅបាននៅដំណាក់កាលដំបូងនេះ គឺជាប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមគ្នាជាក្រុមតែមួយ។ អង្គជំនុំជម្រះទទួលស្គាល់ថាខ្លឹមសារនៃសំណងជាក់លាក់ដែលបានទាមទារអាចមានការកែប្រែនៅពេលក្រោយ ហើយបណ្តឹងទាមទារសំណងជាស្ថាពរអាចមានខ្លឹមសារលម្អិតខុសៗគ្នា (ឯកសារ E86/1)។

ពាក់ព័ន្ធនឹងប្រភេទជាក់លាក់នៃសំណងមួយចំនួន ដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់បឋមក្នុងអំឡុងពេលសវនាការបឋមកាលពីថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់លើចំណុចមួយចំនួនដូចខាងក្រោម ៖

- *ការបង្កើតមូលនិធិស្ម័គ្រចិត្តសម្រាប់អនុវត្តសំណង* (ប្រតិចារឹក, ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១, ទំព័រ ១០៩ (អត្ថបទជាភាសាអង់គ្លេស))៖ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានគូសបញ្ជាក់ថាមូលនិធិស្ម័គ្រចិត្ត និងសំណងជាប្រាក់ជាលក្ខណៈបុគ្គល ពុំស្ថិតនៅក្នុងវិសាលភាពនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ឡើយ (សាលក្រមករណី *ឌុច* កថាខណ្ឌ ៦៧០)។ ក្រោយមកចំណុចនេះក៏មានបញ្ជាក់នៅក្នុងវិធាន២៣*ស្ទួនបួន* (១) ផងដែរ។ ហេតុដូច្នេះ ក្នុងសំណុំរឿងលេខ ០០២ នេះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនពិចារណាទៅលើបណ្តឹងទាមទារសំណងដែលមានលក្ខណៈជាប្រាក់សម្រាប់សមូហភាព ឬជាបុគ្គល ឬការបង្កើតមូលនិធិស្ម័គ្រចិត្តឡើយ។

- *វិធានការនានាដែលតម្រូវឲ្យមានការឯកភាពពីរាជរដ្ឋាភិបាល៖* វិធានការមួយចំនួនដែលបានចង្អុលបង្ហាញដោយសហមេធាវីនាំមុខកាលពីពេលដំបូង គឺអាចហួសពីវិសាលភាពរបស់ អ.វ.ត.ក ក្នុងការសម្រេច ហើយដែលវិធានការទាំងនោះគឺជាបុព្វសិទ្ធិរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេច (សាលក្រមករណី *ឌុច,* កថាខណ្ឌ ៦៦៣, កថាខណ្ឌ ៦៧១, កថាខណ្ឌ ៦៧៤)។ វិធានការទាំងនេះ រួមទាំងការផ្តល់សញ្ជាតិខ្មែរដល់ជនរងគ្រោះជនជាតិវៀតណាម (ប្រតិចារឹក, ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១, ទំព័រ ១០៩ (អត្ថបទជាភាសាអង់គ្លេស)) និងការបង្កើតទិវាចងចាំ (ប្រតិចារឹក, ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១, ទំព័រ១០៧ (អត្ថបទជាភាសាអង់គ្លេស))។ គំនិតផ្តួចផ្តើមដូច្នេះអាចនឹងត្រូវសម្រេចយល់ព្រមដោយអង្គជំនុំជម្រះសាលាដំបូងថាជាសំណងបាន តែក្នុងករណីដែលមានភស្តុតាងបញ្ជាក់ច្បាស់ថា វិធានការទាំងនោះត្រូវបានយល់ព្រម ហើយនឹងត្រូវអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជាតែប៉ុណ្ណោះ ។

- *ការតម្រូវឲ្យមានភាពជាក់លាក់នៃវិធានការផ្សេងទៀត៖* អង្គជំនុំជម្រះកត់សម្គាល់ឃើញថា វិធានការមួយចំនួនផ្សេងទៀតដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំ គឺពុំមានភាពច្បាស់លាស់ដែលអាចឲ្យ

00743672

E125

អង្គជំនុំជម្រះមានលទ្ធភាពបញ្ចេញយោបល់ប្រកបដោយអត្ថន័យនៅដំណាក់កាលនេះបានទេ។ វិធានការទាំងនោះរួមមាន៖ ការកសាងចេតិយនិងទីបូជនីយដ្ឋាន ការអភិរក្សវាលពិឃាត ការបង្កើតកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យសម្រាប់ក្មេងជំនាន់ក្រោយ និងការបង្កើតគម្រោងគាំទ្រផ្លូវចិត្តសម្រាប់ជនរងគ្រោះ និងការបង្កើតមជ្ឈមណ្ឌលដើម្បីផ្តល់សេវាទាំងនេះ និងការបង្កើតសារមន្ទីរ បណ្ណសារ ឬបណ្ណាល័យ នៅភ្នំពេញ (ប្រតិចារឹក, ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១, ទំព័រ ១០៧-១០៩ (អត្ថបទជាភាសាអង់គ្លេស))។ អាស្រ័យលើភាពជាក់លាក់នៃវិធានការនីមួយៗ វិធានការមួយចំនួនតម្រូវឱ្យមានការឯកភាព ឬការអនុញ្ញាតពីរាជរដ្ឋាភិបាល (ខាងលើ) ។ អាស្រ័យទៅតាមវិធានការនីមួយៗដែលបានរៀបរាប់ជាក់ស្តែង ចំណែកវិធានការផ្សេងទៀតអាចជាវិធានការសមស្រប។ ទោះបីជាវិធានការមួយចំនួនអាចត្រូវបានទទួលយក អង្គជំនុំជម្រះសូមរំឭកដល់សហមេធាវីនាំមុខថា បញ្ហាជាក់ស្តែងមួយចំនួនត្រូវតែមានការពិភាក្សាជាមុន ដើម្បីធានាថាសូម្បីសំណងជានិមិត្តរូបតូចមួយក៏ជនរងគ្រោះអាចទទួលបានប្រកបដោយអត្ថន័យនៅក្នុងក្របខ័ណ្ឌពេលវេលាជាធរមាន (*ឧទាហរណ៍ សូមមើលសាលក្រមករណី ឌុច* កថាខណ្ឌ ៦៦៥, ៦៧២, ៦៧៣)។

- ***វិធានការមួយចំនួនដែលស្ថិតក្រោមវិសាលភាពនៃក្របខណ្ឌគតិយុត្តិរបស់អ.វ.ត.ក៖*** វិធានការផ្សេងទៀតដូចជា ការផ្សព្វផ្សាយសាលក្រមសំណុំរឿងលេខ ០០២ និងការចងក្រងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី (ប្រតិចារឹក, ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១, ទំព័រ ១០៩ (អត្ថបទជាភាសាអង់គ្លេស)) ស្រដៀងទៅនឹងវិធានការនានាដែលធ្លាប់បានទទួលស្គាល់ថាជាវិធានការសមស្របអាចអនុវត្តបាននៅក្នុងបរិបទ អ.វ.ត.ក (*សាលក្រមករណី ឌុច* កថាខណ្ឌ ៦៦៧,៦៦៩)។

ដោយហេតុថាបណ្តឹងឧទ្ធរណ៍ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអង្គបុរេជំនុំជម្រះសម្រេចនៅមុនបន្តិចនៃការចាប់ផ្តើមសវនាការបឋម (សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារ D411/3/6, ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១) ទើបអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់នូវចេតនារបស់ខ្លួន ក្នុងការអនុញ្ញាតឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់បន្ថែមនូវខ្លឹមសារនៃសំណងបឋមរបស់ខ្លួននៅពេលក្រោយ (ឯកសារ E86)។

អាស្រ័យហេតុនេះ អង្គជំនុំជម្រះសូមជូនដំណឹងដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីចេតនារបស់ខ្លួនក្នុងការកំណត់កាលបរិច្ឆេទសវនាការនៅថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១១ ដើម្បីផ្តល់ឱកាសឱ្យសហមេធាវីនាំមុខដាក់សំណើបំពេញបន្ថែម ធ្វើបច្ចុប្បន្នភាព និង ក្នុងករណីចាំបាច់ ធ្វើការកែប្រែទៅលើខ្លឹមសារបឋមនៃសំណងដែលបានបញ្ជាក់កាលពីពេលសវនាការបឋម ដោយយោងតាមគោលការណ៍ណែនាំខាងលើ។ ដីកាកំណត់កាលបរិច្ឆេទសវនាការលើបញ្ហានេះនឹងចេញក្នុងរយៈពេលសមស្រប។